# ស្ថានភាពអតិផរណានៅខែមីនា ឆ្នាំ២០១៨

## ក/ អតិផរណាក្នុងប្រទេស

សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅរាជធានីភ្នំពេញក្នុងខែមីនា ឆ្នាំ២០១៨ ពុំមានការប្រែប្រួលទេធៀបនឹងខែមុន ប៉ុន្តែកើនឡើង **២,៣%** បើធៀបនឹងខែដូចគ្នាឆ្នាំមុន។

កំណើនថ្លៃទំនិញជាមធ្យមក្នុងត្រីមាសទី១ ឆ្នាំ២០១៨នេះ មានអត្រា ២,២% ទាបជាងអត្រាកំណើនក្នុងត្រីមាសទី១ ឆ្នាំ២០១៧ ដែលមានអត្រា ៤,២%។ កំណើនទាបនៃសន្ទស្សន៍ថ្លៃទំនិញក្នុងត្រីមាសទី១នេះ ដោយសារកំណើនទាបនៃសន្ទស្សន៍ថ្លៃក្រុមទំនិញអាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង ដែលអត្រាកំណើនជាមធ្យមត្រឹមតែ ១,៩% ទាបជាងត្រីមាសទី១ ឆ្នាំ២០១៧កន្លងទៅ ដែលមានអត្រាកំណើនជាមធ្យម ៥,៩%។ ក្នុងនោះ ក្រុមទំនិញដែលថមថយកំណើនគួរឱ្យកត់សម្គាល់រួមមាន សាច់មានកំណើនជាមធ្យមត្រឹមតែ ០,៩% (ត្រីមាសទី១ ឆ្នាំ២០១៧ មានកំណើនជាមធ្យម ៤,២%) និងផ្លែឈើស្រស់ ០,១% (ត្រីមាសទី១ ឆ្នាំ២០១៧ មានកំណើនជាមធ្យម ៥,៥%), រីឯបន្លែបានធ្លាក់ចុះ ០,៤% (ត្រីមាសទី១ ឆ្នាំ២០១៧ មានកំណើនជាមធ្យម ១៣,៥%)។ *តាមការសង្កេត យើងអាចធ្វើការសន្និដ្ឋានបានថាការថមថយកំណើននេះ មួយផ្នែកអាចបណ្តាលមកពីវិធានការរបស់រាជរដ្ឋាភិបាល លើការបញ្ចុះអត្រាពន្ធនាំចូលនៃសត្វរស់, ត្រី/សត្វរស់ក្នុងទឹក, សាច់សត្វ និងសាច់ត្រី។*

| តារាង ១÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញទាំង១២ក្រុម (%) | ធៀបនឹងខែមុន | ធៀបនឹង១ឆ្នាំមុន |
|---|---|---|
| **មុខទំនិញគ្រប់មុខ** | **+០,០** | **+២,៣** |
| ១-អាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង | +០,១ | +២,២ |
| ២-ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ | -០,១ | -០,៦ |
| ៣-សម្លៀកបំពាក់និងស្បែកជើង | +០,២ | +១,៣ |
| ៤-ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន | -០,២ | +១,៣ |
| ៥-គ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់ | -០,២ | +០,៥ |
| ៦-សុខាភិបាល | +០,២ | +១,២ |
| ៧-ការដឹកជញ្ជូន | -០,៣ | +២,៥ |
| ៨-គមនាគមន៍ | -០,៣ | -១,៥ |
| ៩-ការកំសាន្ត និងវប្បធម៌ | -០,៣ | -១,៩ |
| ១០-ការសិក្សា | ០,០ | -០,៧ |
| ១១-ភោជនីយដ្ឋាន | +០,២ | +៧,៥ |
| ១២-ទំនិញ និងសេវាកម្មផ្សេងៗ | -០,២ | +៣,៦ |

| តារាង ១ ÷ បម្រែបម្រួលសន្ទស្សន៍ថ្លៃម្ហូបអាហារសំខាន់ៗ | | | | | | |
|---|---|---|---|---|---|---|
| មុខទំនិញ | ធៀបខែមុន (%) | | | ធៀបនឹងឆ្នាំមុន (%) | | |
| | ២០១៨ | | | ២០១៨ | | |
| | មករា | កុម្ភៈ | មីនា | មករា | កុម្ភៈ | មីនា |
| អង្ករ | +0,១ | +0,២ | +0,២ | +២,៣ | +២,១ | +២,២ |
| សាច់គោ | -0,៥ | +0,៧ | -0,១ | +២,២ | +២,៨ | +២,៨ |
| សាច់មាន់ | -0,៣ | +១,១ | -0,៨ | -0,៩ | +0,៥ | +0,៦ |
| សាច់ទា | -0,១ | -0,២ | -0,១ | +0,៤ | +0,៩ | +0,៦ |
| សាច់ជ្រូក | +0,៦ | +0,៣ | +0,៥ | -0,២ | +0,៣ | +0,៧ |
| ត្រីទឹកសាប និង ត្រីទឹកសមុទ្រ | -0,១ | +0,៣ | +0,២ | +៤,៣ | +៤,១ | +៤,៥ |
| ក្នុងនោះត្រីស្រស់ | -0,២ | +0,៣ | +0,២ | +៤,៦ | +៤,៤ | +៤,៨ |
| ផ្លែឈើ | -0,៥ | +១,៧ | 0,0 | -0,១ | +១,៧ | +១,៣ |
| ផ្លែឈើស្រស់ | -0,៥ | +១,៨ | -0,១ | -0,៨ | +0,៩ | +0,៣ |
| បន្លែ | -0,៣ | +0,៣ | +0,៣ | -១,៤ | -0,៥ | +0,៧ |
| បន្លែជាស្លឹក | -១,២ | +0,១ | +0,៩ | -១,៧ | -0,៩ | +១,៨ |
| បន្លែជាផ្លែ | +១,៤ | +0,៧ | +0,៥ | -៣,៨ | -១,៦ | -0,៣ |

## ខ/ អតិផរណាប្រចាំឆ្នាំរបស់ប្រទេសមួយចំនួន

| តារាង ៣÷ អតិផរណាចុងឆ្នាំ (Year on Year) គិតជា % | | | | | | |
|---|---|---|---|---|---|---|
| ប្រទេស | ២០១៧ | | | ២០១៨ | | |
| | មករា | កុម្ភៈ | មីនា | មករា | កុម្ភៈ | មីនា |
| ប្រទេសកម្ពុជា | 4.4 | 4.0 | 4.3 | 2.0 | 2.3 | 2.3 |
| ប្រទេសវៀតណាម | 5.2 | 5.0 | 4.7 | 2.7 | 3.2 | 2.7 |
| ប្រទេសថៃ | 1.6 | 1.4 | 0.76 | 0.68 | 0.42 | 0.79 |
| ប្រទេសម៉ាឡេស៊ី | 3.2 | 4.5 | 5.1 | 2.7 | 1.4 | 1.3 |
| ប្រទេសឥណ្ឌូនេស៊ី | 3.5 | 3.8 | 3.6 | 3.3 | 3.2 | 3.4 |
| ប្រទេសហ្វីលីពីន | 2.7 | 3.3 | 3.1 | 4.0 | 3.9 | 4.3 |
| ប្រទេសចិន | 2.5 | 0.8 | 0.9 | 1.5 | 2.9 | 2.1 |
| ប្រទេសកូរ៉េខាងត្បូង | 2.0 | 1.9 | 2.2 | 1.0 | 1.4 | 1.3 |
| ប្រទេសជប៉ុន | 0.4 | 0.3 | 0.2 | 1.4 | 1.5 | 1.1 |

ប្រភពទិន្នន័យ

(១) ប្រទេសកម្ពុជា គឺពីវិទ្យាស្ថានជាតិស្ថិតិ(NIS)

(២) ប្រទេសផ្សេងៗទៀត គឺពីគេហទំព័រ http://www.tradingeconomics.com;

**<u>កំណត់សម្គាល់</u>**

ការចងក្រងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) នៅភ្នំពេញ÷

- ថ្លៃទំនិញដែលត្រូវបានជ្រើសរើសមានចំនួន ២៥៩មុខ
- ថ្លៃមុខទំនិញភាគច្រើនត្រូវបានប្រតិបត្តិការប្រមូលពីផ្សារចំនួន ៥
- ជាទូទៅថ្លៃត្រូវបានប្រមូលពីតូបគំរូចំនួន ៤ក្នុងផ្សារនីមួយៗ
- សម្រាប់មុខទំនិញដែលមិនដាក់លក់នៅទីផ្សារ ថ្លៃត្រូវបានប្រមូលពីតូបនៅជិតៗផ្សារ
- សន្ទស្សន៍ថ្លៃនៃមុខទំនិញត្រូវបានចងក្រងតាមមធ្យមរេខាគណិតសាស្ត្រ (geometric average)

ប្រភព÷ ក្រសួងផែនការ (វិទ្យាស្ថានជាតិស្ថិតិ)

***រៀបចំនិងធ្វើចំណោលដោយ***

***នាយកដ្ឋានស្ថិតិ និងវិភាគសេដ្ឋកិច្ច***

***អគ្គនាយកដ្ឋានគោលនយោបាយ, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ***

*ព័ត៌មានផ្សេងៗ សូមទាក់ទងក្រុមការងារ*

*ទូរស័ព្ទលេខ÷ (+៨៥៥) ២៣ ៤២៧ ៩១៣, (+៨៥៥) ៧៧ ៨៨ ៩៩ ៩២*

*ម៉ោងធ្វើការ÷ ៧:០០ ដល់ ១១:០០ព្រឹក និង ២:០០ ដល់ ៥:០០រសៀល*

*កំណត់សម្គាល់÷*

*ចំពោះមតិដែលបានបង្ហាញក្នុងរបាយការណ៍នេះគឺជាការយល់ឃើញរបស់ក្រុមការងារនៃអគ្គនាយកដ្ឋាន។*

*ការផ្សព្វផ្សាយនេះមិនស្តែងពីការយល់ឃើញរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឬរាជរដ្ឋាភិបាលកម្ពុជានោះទេ។*